សំណើ

# 25 ការធ្វើប្រជាមតិចំពោះច្បាប់ដែលបានជំនួសប្រាក់ធានា ដោយប្រព័ន្ធមួយ ដោយផ្អែកលើសុវត្ថិភាពសាធារណៈ និងហានិភ័យនៃការហោះហើរ។

**ចំណងជើង និងសេចក្តីសង្ខេបជាផ្លូវការ** រៀបចំដោយអគ្គមេធាវី

**អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័ររដ្ឋលេខាធិការនៅ *voterguide.sos.ca.gov*។**

ការបោះឆ្នោត «គាំទ្រ» មានន័យថាឯកភាព ហើយការបោះឆ្នោត «ជំទាស់» មានន័យថាបដិសេធចំពោះច្បាប់ឆ្នាំ 2018 មួយដែល ៖

- ជំនួសប្រព័ន្ធការដាក់ប្រាក់ធានា (ដើម្បីបានការដោះលែងពីពន្ធនាគារមុនពេលកាត់ក្តី) ដោយប្រព័ន្ធមួយ ដែលផ្អែកលើការកំណត់របស់សុវត្ថិភាពសាធារណៈ និងហានិភ័យ នៃការហោះហើរ ។
- ដាក់កម្រិតការឃុំឃាំងបុគ្គលក្នុងពន្ធនាគារ មុនកាត់ក្តីសម្រាប់បទមជ្ឈឹមភាគច្រើន ។

**សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគច្បាប់ស្តីពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋនិងរដ្ឋាភិបាលមូលដ្ឋាន ៖**

- បង្កើនការចំណាយរបស់រដ្ឋ និងមូលដ្ឋាន ដែលអាចមានចំនួនពាក់កណ្តាលរយលានដុល្លាររៀងរាល់ឆ្នាំ សម្រាប់ដំណើរការថ្មីមួយនេះសម្រាប់ការដោះលែងមនុស្សពីពន្ធនាគារ មុនពេលកាត់ក្តី ។ មិនប្រាកដថាតើការកើនឡើងនៃការចំណាយរបស់រដ្ឋខ្លះ នឹងអាចទូទាត់កាត់កងជាមួយមូលនិធិមូលដ្ឋាន ដែលចំណាយនាពេលបច្ចុប្បន្នសម្រាប់ប្រភេទទំហំការងារនេះ ។
- កាត់បន្ថយការចំណាយលើពន្ធនាគារតាមខោនធី ដែលអាចលើសរាប់សិបលានដុល្លាររៀងរាល់ឆ្នាំ ។
- ផលប៉ះពាល់សុរបដែលគេមិនដឹង មកលើប្រាក់ចំណូលពន្ធរដ្ឋ និងមូលដ្ឋាន ដែលជាទូទៅពាក់ព័ន្ធជាមួយមនុស្ស ដែលចំណាយលុយមកលើទំនិញ ជាជាងការបង់ប្រាក់ដើម្បីបានការដោះលែងពីពន្ធនាគារមុនកាត់ក្តី ។

**ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ**

## សាវតា

### ការដោះលែងពីពន្ធនាគារមុនការកាត់ក្តីអាចកើតឡើងតាមពីររបៀប

***ការដាក់ក្នុងពន្ធនាគារ ក្រោយពេល ចាប់ខ្លួន។*** ជនដែលត្រូវបានចោទប្រកាន់ដោយបទល្មើសត្រូវតែចូលរួមក្នុងនីតិវិធីតុលាការជម្រះក្តីមុនពេលធ្វើសវនការជាក់ស្តែងនៅក្នុងតុលាការជំនុំជម្រះ។ នីតិវិធីតុលាការដំបូង—ដែលគេស្គាល់ថាជាការនាំខ្លួនទៅតុលាការ—ពាក់ព័ន្ធនឹងតុលាការដែលប្រាប់ជននោះអំពីការចោទប្រកាន់ដែលបានធ្វើឡើងប្រឆាំងនឹងខ្លួននិងការតែងតាំងមេធាវីប្រសិនបើចាំបាច់។អ្នកដែលត្រូវបានចាប់ខ្លួនខ្លះត្រូវបានយកទៅដាក់ក្នុងពន្ធនាគារខោនធីមុនពេលបញ្ជូនទៅតុលាការ។ នគរបាលខោនធីដែលដំណើរការពន្ធនាគារអាចជ្រើសរើសដោះលែងជននោះភ្លាមៗ ឬដាក់ បុគ្គលនោះនៅក្នុងពន្ធនាគារ។

***ការដោះលែង ពីពន្ធនាគារមុនពេល ជំនុំជម្រះ។*** នៅក្រោម ធម្មនុញ្ញ របស់ រដ្ឋ មនុស្ស ដែលត្រូវ បាន ចាប់ខ្លួន និង ដាក់ ក្នុង ពន្ធនាគារខោនធី—លើកលែង តែ បទឧក្រិដ្ឋមួយចំនួន—មាន សិទ្ធិ អោយដោះលែង មុន ការកាត់ក្តី។ ធម្មនុញ្ញ បញ្ជាក់ថា ជនទាំងនេះ នឹងត្រូវ បានដោះលែង ដោយ មាន លក្ខខណ្ឌ ដែល មិន ហួស ហេតុពេក។ នៅពេល ធ្វើការ សម្រេចចិត្ត ទាក់ទង នឹង ការ ដោះលែង មនុស្ស មុន ជំនុំជម្រះ តុលាការ ជំនុំជម្រះ ត្រូវ ពិចារណា អំពី (1) ភាព ធ្ងន់ធ្ងរ នៃ បទល្មើស ដែល ជននោះត្រូវ បាន ចោទ (2) ប្រវត្តិ បទល្មើស កាលពីមុន របស់ ជននោះ និង (3) លទ្ធភាព ដែល ជននោះ អាច នឹង បង្ហាញ ខ្លួន នៅ ក្នុង តុលាការ។ តុលាការ អាច នឹង ប្រើប្រាស់ ព័ត៌មាន ផ្សេងៗគ្នា រួមមាន ឧបករណ៍ វាយតម្លៃ ហានិភ័យ (មាន ពិភាក្សា លម្អិត នៅខាងក្រោម) ដើម្បីជួយ ធ្វើការ សម្រេចចិត្ត ទាំងនេះ។

នៅក្រោមច្បាប់រដ្ឋជាទូទៅប្រជាជនត្រូវបានដោះលែងពីពន្ធនាគារមុនការកាត់ក្តីតាមវិធីមួយ ឬពីរដូចខាងក្រោម៖

- ***ការ ទទួលស្គាល់ខ្លួនឯង។*** តុលាការជម្រះក្តីអាចដោះលែងជននោះដោយ “ការទទួលស្គាល់ខ្លួនឯង” (ឬ) ដែលជាទូទៅសំដៅលើការសន្យារបស់បុគ្គលនោះថា នឹងបង្ហាញខ្លួននៅឯនីតិវិធីតុលាការដែលត្រូវបានតម្រូវនៅពេលអនាគត ។ នគរបាលខោនធីដែលដំណើរការពន្ធនាគារក៏អាចដោះលែង ប្រជាជន ឬដោះលែងដោយមានលក្ខខណ្ឌផងដែរ។
- ***ប្រាក់ធានា។*** ប្រជាជនអាចត្រូវបានដោះលែងដោយមានប្រាក់ធានា។ប្រាក់ធានាសំដៅលើការធានាផ្នែកហិរញ្ញវត្ថុថាជននោះនឹងបង្ហាញខ្លួននៅតុលាការតាមការតម្រូវ។

***ឧបករណ៍វាយតម្លៃហានិភ័យមុនការកាត់ក្តី។*** ដើម្បីជួយសម្រេចចិត្តថាតើអាចដោះលែងមនុស្សមុនការកាត់ក្តីបានឬទេ តុលាការនិងខោនធីភាគច្រើនប្រើប្រាស់ឧបករណ៍ ដើម្បីប៉ាន់ប្រមាណហានិភ័យ (ឬលទ្ធភាព) ដែលជនដែលត្រូវបានដោះលែងនោះ នឹងប្រព្រឹត្តបទល្មើសថ្មី ឬមិនព្រមបង្ហាញខ្លួននៅតុលាការឬទេ។ ឧបករណ៍ទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែក លើការស្រាវជ្រាវដែលបង្ហាញថាមនុស្ស ដែលមានលក្ខណៈនិស្ស័យជាក់លាក់មួយចំនួន (ដូចជាការនៅវ័យក្មេង) គឺទំនងជានឹងអាចប្រព្រឹត្តបទល្មើសថ្មីឬមិនមកបង្ហាញខ្លួននៅតុលាការ។ ឧបករណ៍នេះផ្តល់ពិន្ទុអាស្រ័យលើ លក្ខណៈនិស្ស័យរបស់មនុស្ស។ ឧទាហរណ៍មួយដាក់ពិន្ទុច្រើនជាងចំពោះមនុស្សដែលមានអាយុក្រោម 22 ឆ្នាំដោយសារពួកគេអាចនឹងប្រព្រឹត្តបទល្មើសច្រើន ជាងមនុស្សចាស់ជាងនោះ។ ដូចគ្នានេះដែរ អ្នកដែលមិនព្រមបង្ហាញខ្លួននៅតុលាការច្រើនដងកាលពីអតីតកាល គឺទំនងជានឹងមិនបង្ហាញខ្លួននៅតុលាការនៅពេលអនាគត ហើយនឹងទទួលបានពិន្ទុច្រើន។ កម្រិតហានិភ័យរបស់មនុស្សម្នាក់ត្រូវបានកំណត់ ដោយចំនួនពិន្ទុសរុបដែលទទួលបាន។ កម្រិតហានិភ័យនេះ បន្ទាប់មកត្រូវ

25

## ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ



បានប្រើប្រាស់ ដើម្បីជួយសម្រេចចិត្តថាតើជននោះគួរត្រូវបានដោះលែង និងក្រោមលក្ខខណ្ឌអ្វី។

### ការដោះលែងដោយមានប្រាក់ធានា

***ចំនួនទឹកប្រាក់ធានាត្រូវបានកំណត់ដោយតុលាការជំនុំជម្រះនីមួយៗ។*** ច្បាប់រដ្ឋតម្រូវថា តុលាការជំនុំជម្រះនៅក្នុងខោនធីនីមួយៗ អនុវត្តតាមកម្មវិធីប្រាក់ធានា។ កម្មវិធីនេះធ្វើបញ្ជីចំនួនទឹកប្រាក់ធានា ដែលត្រូវការសម្រាប់ការដោះលែងបទល្មើសនីមួយៗ។ កម្មវិធីប្រាក់ធានាជាទូទៅអាចខុសគ្នាទៅតាមខោនធី ប៉ុន្តែតម្រូវអោយមានប្រាក់ធានា កាន់តែច្រើនសម្រាប់បទល្មើសកាន់តែធ្ងន់ធ្ងរ។ ឧទាហរណ៍កម្មវិធីប្រាក់ធានាខោនធី Los Angeles ពេលបច្ចុប្បន្នត្រូវការ $20,000 សម្រាប់បទឆបោក និង $250,000 សម្រាប់ការលួចដុតផ្ទះ។

***ប្រាក់ធានាត្រូវបានផ្តល់តាមពីររបៀប។*** វិធីទាំងនេះគឺ៖

- ***ផ្តល់ដោយជននោះទៅតុលាការ។*** ជននោះអាចផ្តល់សាច់ប្រាក់ទ្រព្យសម្បត្តិ ឬសម្ភារៈផ្សេងទៀតទៅតុលាការជំនុំជម្រះដែលស្មើនឹងទឹកប្រាក់ធានាចាំបាច់ សម្រាប់ការដោះលែង។ ប្រាក់នេះជាទូទៅត្រូវបានប្រគល់ទៅជននោះវិញ ប្រសិនបើជននោះបង្ហាញខ្លួននៅតុលាការតាមការតម្រូវ។
- ***ផ្តល់ដោយភ្នាក់ងារប្រាក់ធានា។*** បុគ្គលម្នាក់អាចបង់កម្រៃសេវាដែលមិនអាចដកយកវិញបានទៅភ្នាក់ងារប្រាក់ធានាដើម្បីទិញប័ណ្ណកម្ចីប្រាក់ធានាដែលគាំទ្រដោយក្រុមហ៊ុនធានារ៉ាប់រង។ កម្រៃសេវានេះជាធម្មតាមិនលើសពី10ភាគរយនៃប្រាក់ធានារបស់ជននោះទេ។ ដោយការផ្តល់ប័ណ្ណកម្ចីភ្នាក់ងារប្រាក់ធានាយល់ព្រមបង់ប្រាក់ធានាពេញលេញប្រសិនបើជននោះមិនបង្ហាញខ្លួននៅតុលាការតាមការតម្រូវ។ ប្រសិនបើករណីនេះកើតឡើងភ្នាក់ងារប្រាក់ធានាអាចស្វែងរកការសងប្រាក់ពីបុគ្គលនោះ។

***ការមិនបង្ហាញខ្លួនកម្រនាំមកនូវការបង់ប្រាក់ធានាពេញលេញ ណាស់។*** ប្រសិនបើមនុស្សម្នាក់មិនបង្ហាញខ្លួន នៅតុលាការតាមការតម្រូវទេ តុលាការអាចសម្រេចថាប្រាក់ធានានោះគឺត្រូវបានជំពាក់។ ច្បាប់រដ្ឋកំណត់ថាតើពេលណាដែលប្រាក់ធានាពេញលេញត្រូវតែ បានបង់ឧទាហរណ៍ប្រាក់ធានាមិនត្រូវបានបង់ ប្រសិនបើជននោះត្រឡប់មកជាប់ឃុំតាមការអនុវត្តច្បាប់ ឬដោយបុគ្គលិកស្តារប្រាក់ធានា (ពេល ខ្លះហៅថា "អ្នកប្រមាញ់បំណុល") ក្នុងរយៈពេល 180 ថ្ងៃចាប់ពីថ្ងៃសេចក្តីសម្រេចរបស់តុលាការ ។ ប្រាក់ធានាក៏មិនត្រូវបានបង់នៅក្នុងករណីផ្សេងទៀតដូចជា ប្រសិនបើតុលាការមិនជូនដំណឹងបានត្រឹមត្រូវ ដល់ក្រុមហ៊ុនធានារ៉ាប់រងថា ប្រាក់ធានានោះត្រូវតែបានបង់។ ជាលទ្ធផលប្រាក់ធានាត្រូវបានបង់ពិតប្រាកដតែមួយចំនួនតូចនៃ ករណី តែប៉ុណ្ណោះ។ ខោនធីនិងទីក្រុងទទួលប្រាក់ធានាដែលបានបានបង់នេះ។

***ឧស្សាហកម្មប័ណ្ណកម្ចីប្រាក់ធានាត្រូវបានគ្រប់គ្រងដោយរដ្ឋ។*** នេះរួមមានការផ្តល់អាជ្ញាប័ណ្ណដល់ភ្នាក់ងារប្រាក់ធានាប្រហែល 2,500 ភ្នាក់ងារនិងការត្រួតពិនិត្យប្រាក់សេវា ដែលបានគិតសម្រាប់ប័ណ្ណបំណុលប្រាក់ធានាដែលបានកំណត់ ដោយក្រុមហ៊ុនធានារ៉ាប់រងប្រហែល 20 ដែលគាំទ្រដល់ប័ណ្ណកម្ចីទាំងនោះ។ រដ្ឋក៏ស៊ើបអង្កេតនិងអាចដោះស្រាយបណ្តឹងតាមបែបរដ្ឋបាលផងដែរប្រឆាំងនឹងភ្នាក់ងារ ប្រាក់ធានានិងក្រុមហ៊ុនធានារ៉ាប់រង។ លើសពីនោះរដ្ឋធ្វើការ ជាមួយរដ្ឋាភិបាលក្នុងមូលដ្ឋានដើម្បីកាត់ទោស ការរំលោភបំពាន ព្រហ្មទណ្ឌដោយភ្នាក់ងារប្រាក់ធានា និងដោយក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងតុលាការ។ រដ្ឋគិតកម្រៃសេវាដើម្បីជួយដល់ការចំណាយផ្នែកបញ្ញត្តិកម្ម។

កាលពីឆ្នាំ 2018 ឧស្សាហកម្មប្រាក់ធានាបានចេញប័ណ្ណកម្ចីប្រាក់ធានាដែលមានទឹកប្រាក់ប្រហែល $6 ពាន់លាននិងបានប្រមូលថ្លៃកម្រៃសេវាប័ណ្ណកម្ចីប្រាក់ធានាប្រហែល $560 លាន។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបានតម្រូវឲ្យបង់ 2.4 ភាគរយសម្រាប់ជាពន្ធធានា រ៉ាប់រងចូលរដ្ឋលើថ្លៃសេវាទាំងនោះ—ប្រហែល $13 លានកាលពីឆ្នាំ 2018។

### ការដោះលែងពីពន្ធនាគារអាចកើតឡើង នៅក្នុងពេលផ្សេងគ្នាមុនពេលជំនុំជម្រះ

***ដំណើរការដោះលែងមុនពេល បញ្ជូនខ្លួនទៅតុលាការ។*** មនុស្សអាចត្រូវបានដោះលែងពីពន្ធនាគារ មុនពេលបញ្ជូនខ្លួនទៅតុលាការក្រោយពីការផ្តល់ប្រាក់ធានា ដូចនៅក្នុងកម្មវិធីប្រាក់ធានាសម្រាប់បទល្មើសជាក់លាក់។ នៅក្នុងខោនធីខ្លះតុលាការជំនុំជម្រះអាចអនុញ្ញាតឲ្យ ស្ថាប័នផ្សេងទៀត (ដូចជានាយកដ្ឋានការដោះលែងសាកល្បងដោយ មានលក្ខខណ្ឌ) ដើម្បីដោះលែងមនុស្សជាក់លាក់ឬមុនពេលបញ្ជូនខ្លួនទៅតុលាការ។ មនុស្សទាំងនោះអាចត្រូវបានតម្រូវអោយគោរព លក្ខខណ្ឌជាក់លាក់ (ដូចជាការទៅជួបជាប្រចាំជាមួយបុគ្គលិកផ្នែកដោះលែងសាកល្បងប្រចាំខោនធី)។ អ្នកដែលមិនផ្តល់ប្រាក់ធានា ឬ ដែលមិនត្រូវបានដោះលែង ឬត្រូវបានឃុំខ្លួនរហូតដល់បញ្ជូនខ្លួនទៅ តុលាការ។

***ដំណើរការដោះលែងក្រោយពេលបញ្ជូនខ្លួនទៅតុលាការ។*** នៅពេលការបញ្ជូនខ្លួនតុលាការសម្រេចចិត្តថាតើត្រូវ (1) រក្សាជននោះនៅក្នុងមន្ទីរឃុំឃាំង (2) ផ្លាស់ប្តូរចំនួនទឹកប្រាក់ធានាសម្រាប់ការដោះលែង ឬ (3) ដោះលែងជននោះដោយមានការទទួលស្គាល់ខ្លួនឯង។ អ្នកដែល មិនត្រូវបានដោះលែង ឬនិងមិនអាចផ្តល់ប្រាក់ធានាដែលត្រូវបានតម្រូវជាទូទៅត្រូវដាក់នៅមន្ទីរឃុំឃាំងប្រចាំខោនធី។ តុលាការអាចតម្រូវឲ្យអ្នកដែលត្រូវបានដោះលែងគោរពតាមលក្ខខណ្ឌមួយចំនួន។ ក្នុងករណីខ្លះ ជននោះត្រូវបានគិតកម្រៃសេវាពាក់ព័ន្ធនឹងការដោះលែងមុនការកាត់ក្តី។ ឧទាហរណ៍មនុស្សម្នាក់អាចនឹងត្រូវបានគិតប្រាក់សម្រាប់ថ្ងៃតាមដាន ដោយប្រព័ន្ធអេឡិចត្រូនិកដែលអាចជា លក្ខខណ្ឌចេញដោយតុលាការ។ តុលាការអាចកែតម្រូវសេចក្តីសម្រេចទាំងនេះ រហូតដល់ថ្ងៃកាត់ក្តី ឬរហូតដល់សំណុំរឿងត្រូវបានដោះស្រាយរួច។

### អត្ថបទនៃប្រាក់ធានាថ្មីនិងច្បាប់បុរេជំនុំជម្រះកាលពីឆ្នាំ 2018

កាលពីឆ្នាំ 2018 រដ្ឋសភាបានអនុម័ត ហើយអភិបាលបានចុះហត្ថលេខាលើច្បាប់—ច្បាប់ព្រឹទ្ធសភា (SB) 10—ដើម្បីលុបបំបាត់ប្រាក់ធានានិង ផ្លាស់ប្តូរដំណើរការសម្រាប់ការទទួលបាន ការដោះលែងពីមន្ទីរឃុំឃាំងមុនពេលជំនុំជម្រះ។ ច្បាប់នេះចាប់ផ្តើមចូលជាធរមាននៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019។ ទោះយ៉ាងណាវាមិនបានកើតឡើងទេ ព្រោះតែប្រជាមតិស្តីពី SB 10 មានលក្ខណៈសម្បត្តិសម្រាប់សន្លឹកឆ្នោតនេះ កាលពីខែមករា ឆ្នាំ 2019។ នៅក្រោមធម្មនុ

## ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

បន្ត

ញ្ញរដ្ឋនៅពេលប្រជាមតិស្តីពីច្បាប់ថ្មីមាន គុណសម្បត្តិសម្រាប់សន្លឹកឆ្នោតច្បាប់នោះនឹងត្រូវព្យួរទុករហូត ដល់ពេលអ្នកបោះឆ្នោតកំណត់ថាតើត្រូវដាក់វាចូលជាធរមានឬទេ។

# សំណើ

***កំណត់ថាតើប្រាក់ធានាថ្មីនិងច្បាប់បុរេជំនុំជម្រះចូលជាធរមានឬទេ។*** សំណើ 25 គឺជាប្រជាមតិស្តីពី SB 10 ហើយនឹងកំណត់ថាតើច្បាប់នឹងចូលជាធរមានឬទេ។ ការបោះឆ្នោត "គាំទ្រ" មានន័យថា SB 10 នឹងចូលជាធរមាន ហើយការបោះឆ្នោត "បដិសេធ" នឹងច្រានចោល SB 10។ និយាយឲ្យជាក់លាក់ការយល់ព្រមចំពោះសំណើនេះនឹង (1) លុបបំបាត់ការដោះលែងដោយប្រាក់ធានា (2) បង្កើតដំណើរការថ្មី សម្រាប់ការដោះលែងមុនបញ្ជូនខ្លួនទៅតុលាការ និង (3) ផ្លាស់ប្តូរដំណើរការដែលមានស្រាប់សម្រាប់ការដោះលែងនៅពេលបញ្ជូនខ្លួនទៅតុលាការ។

## លុបបំបាត់ការដោះលែងដោយមានប្រាក់ធានា

សំណើ 25 លុបបំបាត់ការដោះលែងពីមន្ទីរឃុំឃាំងខោនធីដោយប្រាក់ធានាមុនពេលការកាត់ក្តី។

## បង្កើតដំណើរការថ្មីសម្រាប់ការដោះលែងមុនពេលបញ្ជូនខ្លួនទៅតុលាការ

***តម្រូវឲ្យមានការដោះលែងដោយស្វ័យប្រវត្តិ សម្រាប់បទល្មើសមជ្ឈិមភាគច្រើន។*** សំណើនេះតម្រូវឲ្យមនុស្សស្ថិតនៅក្នុងមន្ទីរឃុំឃាំងខោនធី សម្រាប់បទល្មើសមជ្ឈិមភាគច្រើនដែលជាបទល្មើស មិនសូវ ធ្ងន់ធ្ងរឲ្យដោះលែង ដោយស្វ័យប្រវត្តិក្នុងរយៈពេល 12 ម៉ោងក្រោយឃុំខ្លួន។ មនុស្សមួយចំនួនដែលត្រូវបានឃុំខ្លួនដោយបទមជ្ឈិមដូចជា ជនដែលត្រូវបានដាក់ នៅក្នុងមន្ទីរឃុំឃាំងសម្រាប់អំពើហិង្សា ក្នុង គ្រួសារឬអ្នកដែលមិនព្រមបង្ហាញខ្លួននៅតុលាការច្រើនជាងពីរដង កាលពីឆ្នាំមុននឹងមិនត្រូវបានដោះលែងដោយស្វ័យប្រវត្តិទេ។

***ការដោះលែងសម្រាប់ករណីបទឧក្រិដ្ឋនិងបទមជ្ឈិមខ្លះតម្រូវឲ្យមានការវាយតម្លៃ។*** សំណើប្រជាមតិនេះតម្រូវថា អ្នកដែលត្រូវបានដាក់នៅក្នុងមន្ទីរឃុំឃាំងដោយសារ (1) បទឧក្រិដ្ឋ និង (2) បទមជ្ឈិមដែលមិនមានសិទ្ធិទទួលបានការដោះលែង ដោយស្វ័យប្រវត្តិត្រូវទទួលការវាយតម្លៃលើហានិភ័យ របស់ពួកគេក្នុងការប្រព្រឹត្ត បទល្មើសថ្មីឬការមិនបង្ហាញខ្លួននៅតុលាការ ប្រសិនបើដោះលែង។ បុគ្គលិកវាយតម្លៃ នឹងប្រមូលព័ត៌មានមួយចំនួនរួមមានកម្រិតហានិភ័យរបស់បុគ្គលម្នាក់ៗតាមការកំណត់ ដោយឧបករណ៍វាយតម្លៃហានិភ័យមុនពេលជំនុំជម្រះ។ ជាទូទៅបុគ្គលិកត្រូវបានតម្រូវអោយដោះលែងមនុស្ស ប្រសិនបើរកឃើញថាមានហានិភ័យទាប។ អាស្រ័យលើវិធានដែលបានកំណត់ដោយតុលាការជំនុំជម្រះនិមួយៗ មនុស្សដែលមានហានិភ័យមធ្យមក៏ត្រូវបានដោះលែងផងដែរ ដោយបុគ្គលិកវាយតម្លៃ ឬដោយចៅក្រម ។ មនុស្សដែលត្រូវដោះលែងត្រូវតែគោរពតាមលក្ខខណ្ឌជាក់លាក់។ លក្ខខណ្ឌទាំងនេះអាច រួមមានការត្រួតពិនិត្យដូចជាការទៅជួបជាទៀងទាត់ជាមួយ បុគ្គលិកផ្នែកដោះលែងសាកល្បងក្នុងខោនធី ឬការតាមដានដោយអេឡិចត្រូនិក។ ទោះជាយ៉ាងណាលក្ខខណ្ឌ សម្រាប់មនុស្សដែលមានហានិភ័យទាបមិនរួមបញ្ចូលការត្រួតពិនិត្យទេ។ តុលាការអាចផ្លាស់ប្តូរលក្ខខណ្ឌបាន ប្រសិនបើ ជាមូលហេតុល្អ។ មិនដូចជាច្បាប់បច្ចុប្បន្នទេ វាមិនមានការគិតកម្រៃសេវា ជាលក្ខខណ្ឌ នៃការដោះលែងឡើយ។ មនុស្សដែលមានហានិភ័យខ្ពស់ហានិភ័យមធ្យមដែលមិនត្រូវបានដោះលែង និងអ្នកមួយចំនួនទៀត (ដូចជាអ្នកដែលត្រូវបានចោទពីបទឧក្រិដ្ឋឧធ្ងន់ធ្ងរ ដូចជាឃាតកម្មឬ ដុតផ្ទះ) នឹងនៅតែជាប់មន្ទីរឃុំឃាំងខោនធី រហូតដល់ពេលបញ្ជូនខ្លួនទៅតុលាការ។ ការវាយតម្លៃនិងការដោះលែងណាមួយនឹងចាំបាច់ត្រូវបញ្ចប់មិនលើសពី 36 ម៉ោងពីពេលដែលជននោះត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងឡើយ។

***តុលាការជំនុំជម្រះទទួលខុសត្រូវសម្រាប់ការវាយតម្លៃមុនជំនុំជម្រះ។*** សំណើ 25 ធ្វើឲ្យតុលាការកាត់ក្តីប្រចាំរដ្ឋទទួលខុសត្រូវសម្រាប់ការវាយតម្លៃមុនជំនុំជម្រះ។ នេះរួមមានសកម្មភាពផ្សេងៗ ដូចជា ៖ (1) ការកំណត់កម្រិតហានិភ័យដោយប្រើឧបករណ៍ប៉ាន់ប្រមាណហានិភ័យបុរេជំនុំជម្រះ (2) ការប្រមូលព័ត៌មានបន្ថែមទាក់ទងនឹងហានិភ័យរបស់មនុស្ស (3) ការដោះលែងមនុស្ស ជាក់លាក់អាស្រ័យលើកម្រិតហានិភ័យរបស់ពួកគេ និង (4) ការផ្តល់ យោបល់អំពីលក្ខខណ្ឌនៃការដោះលែងមុនជំនុំជម្រះជូនទៅតុលាការ។ តុលាការជំនុំជម្រះអាចប្រើប្រាស់បុគ្គលិកតុលាការ ជាបុគ្គលិកវាយតម្លៃ ឬចុះកិច្ចសន្យាជាមួយទីភ្នាក់ងារសាធារណៈក្នុងមូលដ្ឋាន (ដូចជានាយកដ្ឋានដោះលែង ដោយមានលក្ខខណ្ឌប្រចាំខោនធី) ដើម្បីអនុវត្តសកម្មភាពទាំងនេះ។ ប្រសិនបើទាំងតុលាការ ឬ ទីភ្នាក់ងារសាធារណៈក្នុងមូលដ្ឋានមិនចង់ ឬមិនអាចធ្វើដូច្នេះបានទេ តុលាការអាចចុះកិច្ចសន្យាជាមួយទីភ្នាក់ងារសាធារណៈ ក្នុងមូលដ្ឋានថ្មីដែលបានបង្កើតឡើង សម្រាប់តែអនុវត្តសកម្មភាពនេះបាន។

## ផ្លាស់ប្តូរដំណើរការសម្រាប់ការដោះលែងពេលបញ្ជូនខ្លួនទៅតុលាការ

នៅពេលបញ្ជូនខ្លួនអ្នកជាប់ឃុំអាចត្រូវបានដោះលែង ដោយមានការទទួលស្គាល់ខ្លួនឯង។ មេធាវីមណ្ឌលអាចស្នើសុំសវនការ ដើម្បីឃុំខ្លួនមនុស្សក្នុងមន្ទីរឃុំឃាំង រហូតដល់ពេលកាត់ក្តី ទោះពួកគេត្រូវបានដោះលែងពីមុនរួចហើយក៏ដោយ។ មនុស្សនឹងត្រូវដោះលែងតែក្នុងកាលៈទេសៈជាក់លាក់តែប៉ុណ្ណោះ—ដូចជាប្រសិនបើតុលាការបានសម្រេចថាមិនមានលក្ខខណ្ឌ ដែលអាចធានាថាពួកគេនឹងមិនប្រព្រឹត្តបទល្មើស ឬមិនបង្ហាញខ្លួននៅក្នុងតុលាការ។ អ្នកដែលត្រូវ បានដោះលែងអាចត្រូវបានតម្រូវឲ្យអនុវត្តតាមលក្ខខណ្ឌជាក់លាក់ ប៉ុន្តែមិនអាចត្រូវបានគិតកម្រៃសេវាជាលក្ខខណ្ឌ នៃការដោះលែងទេ។ ក្រោយពេលបញ្ជូនខ្លួនទៅតុលាការមេធាវីមណ្ឌល ឬអ្នកការពារក្តីសាធារណៈអាចស្នើសុំសវនការឃុំខ្លួន នៅក្នុងកាលៈទេសៈជាក់លាក់ដូចជាប្រសិនបើមានភស្តុតាងថ្មី នៅក្នុងសំណុំរឿង។ តុលាការអាចកែតម្រូវការសម្រេចចិត្តចំពោះការទទួលស្គាល់ខ្លួនឯង និង លក្ខខណ្ឌនៃការដោះលែងនៅក្នុងកាលៈទេសៈ ជាក់លាក់ដូចជាប្រសិនបើព័ត៌មានថ្មី ត្រូវបានផ្តល់ដោយបុគ្គលិកវាយតម្លៃបុរេជំនុំជម្រះ។

## ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

បន្ត

# ផលប៉ះពាល់សារពើពន្ធ

សំណើ 25នឹងប៉ះពាល់លើការចំណាយទាំងថ្នាក់រដ្ឋនិងមូលដ្ឋាន។ ទំហំនៃផលប៉ះពាល់ពិតប្រាកដ គឺមិនច្បាស់លាស់ទេហើយនឹងអាស្រ័យលើរបៀប ដែលសំណើនេះត្រូវបានបកស្រាយនិងអនុវត្ត។ ឧទាហរណ៍វាមិនទាន់ច្បាស់ថាតើមនុស្សប៉ុន្មាននាក់ ដែលតុលាការ នឹងដោះលែងមុនពេលជំនុំជម្រះ ហើយនឹងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ។ ដូច្នេះឥទ្ធិពលអាចនឹងខ្ពស់ជាង ឬទាបជាងការប៉ាន់ស្មានខាងក្រោម។

***បន្ទុកចំណាយលើការដោះលែងមុនជំនុំជម្រះថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋានដែលកើនឡើង។*** ដំណើរការនៃការដោះលែងមុនជំនុំជម្រះថ្មី នឹងបង្កើនបន្ទុកការងារសម្រាប់តុលាការជំនុំជម្រះ ប្រចាំរដ្ឋក៏ដូចជាមេធាវីមណ្ឌលខោនធីនិងអ្នកការពារក្ដីសាធារណៈ។ ឧទាហរណ៍នឹង មានបន្ទុកការងារពាក់ព័ន្ធនឹងសវនការឃុំខ្លួនថ្មី។ វានឹងបង្កើនបន្ទុកការងារដែលអាចត្រូវបានកាត់កង ដោយការកាត់បន្ថយបន្ទុកការងារ ផ្សេងទៀត។ ឧទាហរណ៍បន្ទុកការងារពីសវនការ អំពីចំនួនទឹកប្រាក់ ធានាដែលចាំបាច់នឹងត្រូវបានលុបបំបាត់ចោល។

លើសពីនេះការចំណាយរបស់រដ្ឋនឹងកើនឡើង ដោយសារតុលាការ ជំនុំជម្រះប្រចាំរដ្ឋនឹងទទួលខុសត្រូវ លើការវាយតម្លៃបុរេជំនុំជម្រះ។ រដ្ឋក៏ទំនងជានឹងមានការកើនឡើងនូវ ការចំណាយលើការត្រួតពិនិត្យដូចជា ដោយសារតែការកើនឡើងនៃចំនួនមនុស្សត្រូវស្ថិតក្រោមការត្រួតពិនិត្យ បន្ទាប់ពីដោះលែងនៅមុនពេលជំនុំជម្រះ។

សរុបមក **ការចំណាយដែលកើនឡើងពេលមុនជំនុំជម្រះថ្នាក់រដ្ឋនិងមូលដ្ឋានអាចមានចំនួនពាក់កណ្ដាលរាប់រយលានដុល្លារក្នុងមួយឆ្នាំ**។ ទឹកប្រាក់នេះគឺតិចជាង 1 ភាគរយនៃថវិកាមូលនិធិទូទៅបច្ចុប្បន្នរបស់រដ្ឋ។ទំហំពិតប្រាកដនៃការកើនថ្លៃចំណាយនឹងអាស្រ័យលើកត្តាជាច្រើន។ កត្តាធំៗរួមមានចំនួនមនុស្សដែលត្រូវបានដោះលែងមុនជំនុំជម្រះលក្ខខណ្ឌនៃការដោះលែងពួកគេ (ដូចជាត្រូវមានការត្រួតពិនិត្យច្រើនប៉ុនណា) និងថ្លៃចំណាយលើលក្ខខណ្ឌទាំងនេះ។ វាមិនទាន់ច្បាស់ទេថាតើការចំណាយមួយចំនួនរបស់រដ្ឋដែលកើនឡើងនេះនឹងត្រូវទូទាត់ដោយការចំណាយរបស់រដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលមានស្រាប់សម្រាប់បន្ទុកការងារមុនពេលជំនុំជម្រះឬយ៉ាងណា។

***ការចំណាយលើមន្ទីរឃុំឃាំងប្រចាំខោនធី ដែលថយចុះ។*** សំណើនេះនឹងកាត់បន្ថយចំនួនមនុស្សក្នុងមន្ទីរឃុំឃាំងខោនធី។ នេះភាគច្រើនគឺដោយសារតែមនុស្សកាន់តែច្រើន ទំនងជានឹងត្រូវបានដោះលែងមុនពេលជំនុំជម្រះដោយការសារ ការទទួលស្គាល់ខ្លួនឯងជាជាងបន្តនៅជាប់ឃុំ។ ឧទាហរណ៍មនុស្សខ្លះ ដែលនឹងមិនអាចបង់ប្រាក់ធានា នឹងត្រូវដោះលែងនៅក្រោមដំណើរការមុនជំនុំជម្រះថ្មី។ ទោះយ៉ាងណាការធ្លាក់ចុះខ្លះនេះនៃចំនួនមនុស្ស ក្នុងពន្ធនាគារអាចត្រូវបានប៉ះប៉ូវដោយកត្តាផ្សេងទៀត។ ឧទាហរណ៍មនុស្សខ្លះ— ដែលបើពុំនោះសោត ត្រូវបានដោះលែងដោយប្រាក់ធានា— អាចនឹងត្រូវឃុំខ្លួន រហូតដល់ ពេលជំនុំជម្រះ។ ចំនួនជាក់ស្ដែងយើងប៉ាន់ស្មានថា ការកាត់បន្ថយ ចំនួនអ្នកជាប់ឃុំនឹងបន្ថយការចំណាយនៅមន្ទីរឃុំឃាំងប្រចាំខោនធីក្នុងមូលដ្ឋាន ដែលអាចមានតម្លៃរាប់សិបលានដុល្លារ ក្នុងមួយ ឆ្នាំ។ ការថយចុះជាក់ស្ដែង នឹងអាស្រ័យលើចំនួនមនុស្សជាប់ឃុំក៏ដូចជាការសម្រេចចិត្តដោះលែង ដោយតុលាការ។ ធនធានទាំងនេះអាចនឹងត្រូវបង្វែរទៅកសកម្មភាពផ្សេងទៀតនៅក្នុងខោនធី។

***ផលប៉ះពាល់លើចំណូលពន្ធថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋាន។*** សំណើនេះ នឹងប៉ះពាល់ទាំងចំណូលពន្ធថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។ ម្យ៉ាងទៀត វានឹងកាត់បន្ថយចំណូលថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋាន។ ឧទាហរណ៍ ក្រុមហ៊ុនធានារ៉ាប់រងនឹងលែងបង់ពន្ធ លើប័ណ្ណកម្មីប្រាក់ធានា។ ផ្ទុយទៅវិញចំណូលពន្ធថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋានអាចនឹងកើនឡើង។ ឧទាហរណ៍មនុស្សអាចទិញទំនិញ ជាមួយនឹងលុយដែលគេមិនបង់ទៅលើថ្លៃប័ណ្ណកម្មីប្រាក់ធានា។ ប្រសិនបើទំនិញទាំងនេះត្រូវបង់ពន្ធពីការលក់ នោះវានឹងបង្កើនចំណូលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។ ផលប៉ះពាល់សរុបលើចំណូលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានគឺមិនទាន់ដឹងទេ។

**ចូលមើល *http://cal-access.sos.ca.gov/campaign/measures/* សម្រាប់បញ្ជី នៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។**

**ចូលមើល *http://www.fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលប្រើអ្នករួមបរិច្ចាកទានកំពូលៗទាំង 10 រូបសម្រាប់គណៈកម្មការ។**

**ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋនេះ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។**